# សាកល្បងសិក្សាបច្ឆិមបទឬផ្នត់ចុងនៅក្នុងភាសាខ្មែរ

ដោយបេក្ខជនបណ្ឌិតៈ វង្ស មេង មន្ត្រីវិទ្យាស្ថានភាសាជាតិ
E-mail: meng_ifl@yahoo.com
គេហទំព័រៈ http://inl-rac.blogspot.com
លេខទូរសព្ទៈ ០១២ ៨៤៦ ៨១៦

## សេចក្តីផ្តើម

បច្ឆិមបទសមមូលទៅនឹងពាក្យ «suffix» នៃភាសាអង់គ្លេសនិង «suffixe» នៃភាសាបារាំង ។ បច្ចេកស័ព្ទនេះមានការប្រើប្រាស់នៅក្នុងស្នាដៃរបស់លោក កេង វ៉ាន់សាក់ នៅក្នុងមូលភាពនៃការបង្កើតពាក្យថ្មី» ដោយលោកបានពិពណ៌នាថាៈ

*«បច្ឆិមបទគឺជាអព្ភាសបទដែលគេបន្ថែមភ្ជាប់ពីខាងក្រោយធាតុសព្ទ ដើម្បីកែ ប្រែន័យដើមនៃធាតុសព្ទនេះ ហើយ ធ្វើឱយក្លាយទៅជាពាក្យផ្សេងៗទៀត ក្នុង កម្រងពាក្យណាមួយ។» នៅក្នុងភាសាខ្មែរសុទ្ធៗ ពុំមានបច្ឆិមបទទេ ពីព្រោះភាសាខ្មែរ ពុំមែនជាភាសាបិតនៅលើការបំបែកសព្ទ ជា វិភត្តិ ប៉ុន្តែ គឺជា អវិភត្តិ ភាសា«Langue indéclinable» ។»*[1]

តាមន័យនេះ បច្ឆិមបទក៏ជាកម្មេចពាក្យផងដែរ ដោយគ្រាន់តែជាការបង្ហាញខាងលើទំនងជាមានលក្ខណៈទូលំទូលាយ។ ពិតណាស់ថា បច្ឆិមបទក៏ជាអព្ភាសបទ ក៏ប៉ុន្តែវាមិនមែនបង្កើតឲ្យទៅជាកម្រងពាក្យណាមួយនោះទេ បច្ឆិមបទគឺសម្រាប់បង្កើតពាក្យកម្លាយ ហើយ ពាក្យកម្លាយទាំងនោះមានការពាក់ព័ន្ធទៅនឹងពាក្យឫសដែលជាមូលដ្ឋាន។ យើងយល់ស្របតាមគំនិតរបស់លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ពីព្រោះ ភាសាខ្មែរសុទ្ធមិនមានប្រើបច្ឆិមបទ[2]នោះទេ ក៏ប៉ុន្តែ យើងអាចរកឃើញ បច្ឆិមបទនៅក្នុងភាសាខ្មែរបុរាណ ហើយបច្ឆិមបទទាំងនោះមាន

---

1 កេង វ៉ាន់សាក់ ***មូលភាពនៃការបង្កើតពាក្យថ្មី*** ដ.ឯ.ម. ទំព័រ១៥០។

2 លោក អៀវ កើស និងលោកសាស្ត្រាចារ្យ ព្រុំ ម៉ល់ ក៏មានគំនិតស្របគ្នានេះផងដែរថា ភាសាខ្មែរស្ថិតក្នុងអំបូរមន-ខ្មែរ មិនមានការប្រើប្រាស់បច្ឆិមបទនោះទេ។ សូមមើល អៀវ កើស ***ភាសាខ្មែរ(សាកល្បងដោយរកហេតុផល)*** ដ. ឯ.ម. ទំព័រ ១៦៨-១៦៩ និង ព្រុំ ម៉ល់ ***វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប*** ការផ្សាយរបស់អ្នកនិពន្ធ ដ.ឯ.ម. ។

ដូចជា៖ -ក, -ង, -រ, និង -ស។[3]

ឧទាហរណ៍

| | | |
|---|---|---|
| លើ | > | លើង |
| លើ | > | លើក |
| លើ | > | លើស |
| បែរ | > | បែង |
| បែរ | > | បែក |
| បែរ | > | បែស |
| ចា | > | ចាក |
| ចា | > | ចារ។ |

ទន្ទឹមគ្នាផងដែរ សាស្ត្រាចារ្យ បណ្ឌិត ឡុង សៀម បានអះអាងផងដែរថា[4]៖

*«នៅក្នុងភាសាខ្មែរបុរាណជាពិសេសនៅក្នុងអត្ថបទសិលាចារឹក បច្ឆិមបទសឹង តែគ្មានគឺមានសេសសល់ ក្នុងពាក្យមួយចំនួនដំបូងៗនៃសតវត្សទី៧។ គឺបាន សេចក្តីថា ក្នុងភាសាខ្មែរបុរាណ ការប្រើប្រាស់បច្ឆិមបទ នៅមានកម្រិត។ ក្រោយមក បច្ឆិមបទត្រូវបាត់បង់ ដោយសារការប្រើប្រាស់បុព្វបទនិងអន្តបទ កាន់តែច្រើនឡើងៗនិងដោយសារការវិវឌ្ឍន៍ថ្មីៗរបស់វា។»*

ជាសន្និដ្ឋាន យើងអាចយកនិយមន័យមួយរបស់គណៈកម្មាធិការជាតិភាសាខ្មែរដែលបានអនុម័តរួចហើយដែលមានខ្លឹមសារទាំងស្រុងដូចតទៅ[5]៖

«បច្ឆិមបទឬផ្នត់ចុងគឺជាអក្ខរាសបទឬផ្នត់មួយបែបដែលគេដាក់នៅខាងចុងនៃ ពាក្យដើម្បីបង្កើតពាក្យកម្លាយ។ ក្នុងភាសាអង់គ្លេស បច្ឆិមបទ -ly ភ្ជាប់នឹង គុណនាម slow បង្កើតបានជាកិរិយាវិសេសន៍ slowly។ ក្នុងភាសាបារាំង បច្ឆិម បទ -ment ភ្ជាប់នឹងគុណនាម lent បង្កើតបានជាកិរិយាវិសេសន៍ lentement។ តាមមតិទូទៅ ភាសាខ្មែរសុទ្ធគ្មានបច្ឆិមបទទេ

3 Georges Maspero, ***Grammaire de La Langue Khmère***, Paris: Impremerie Nationale, 1915, pp.193-194.

4 ឡុង សៀម «ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទ តាមបម្រើបម្រាស់ផ្នត់នីយកម្ម» នៅក្នុង***សន្និសីទជាតិស្តីពីការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ*** រៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ៧-៩ កញ្ញា ២០០៩ ទំព័រ១១។

5 គណៈកម្មាធិការជាតិភាសាខ្មែរ ***កំណត់ហេតុនៃគណៈកម្មាធិការជាតិភាសាខ្មែរ*** ចុះថ្ងៃពុធ ទី១០ ខែមីនា ឆ្នាំ ២០១០ ទំព័រ៤-៥។

ប៉ុន្តែ ពាក្យខ្មែរដែលកើតពីធាតុ បាលី-សំស្ក្រឹតមានប្រើបច្ឆិមបទ ដូចជា៖

– ពល + [-ករ] > ពលករ
– នគរ + [-ឧបនីយកម្ម] > នគរូបនីយកម្ម។»

## ១. ការវិភាគបច្ឆិមបទខ្មែរបុរាណ -ក, -ខ, -រ និង-ស

បច្ឆិមបទទាំងបួនខាងលើកើតមានឡើងនៅក្នុងសម័យបុរាណ យើងយល់ថាបច្ឆិមបទទាំងអស់នោះពិតជាសម្បូរណាស់ ក៏ប៉ុន្តែ បច្ឆិមបទទាំងនេះលែងកើតមានតទៅទៀតហើយ នៅក្នុងភាសាខ្មែរទំនើប ពីព្រោះភាសាខ្មែរទំនើបបច្ចុប្បន្ន បច្ឆិមបទទាំងនោះក្លាយទៅជាព្យញ្ជនៈប្រកបអស់ទៅហើយ។ ការវិវត្តនេះទំនងជាដំណើរការមួយឈានទៅរកអភិវឌ្ឍភាសាខ្មែរ ដោយសារថា ការប្រើប្រាស់បច្ឆិមបទនាសម័យនោះ នាពេលបច្ចុប្បន្នក៏បានឆ្លុះបញ្ចាំងអំពីន័យនៅក្នុងសម័យបុរាណផងដែរ។

### ១.១. បច្ឆិមបទខ្មែរបុរាណ -ក

យើងអាចសង្កេតមើលន័យនិងការប្រើប្រាស់របស់ពាក្យ«លើនិងលើក» ដូចខាងក្រោមតាមវចនានុក្រមខ្មែរ៖

– លើ ( និ. ) ខាងខ្ពស់, ដែលជាប៉ែកខាងខ្ពស់ : លើដំបូល, លើរាន, លើគោក ។ ចំពោះត្រង់ : ចាប់មន្ទិលលើមនុស្សម្នាក់ ។ ប្រើអំណាចឆ្ពោះទៅរក : ត្រួតត្រាលើ, និយាយលើ ។ល។ អា. និ. ពាក្យសម្រាប់ទទួលរងដំណើរអំពីអកម្មកិរិយាមានពាក្យ ដេក, អង្គុយ ជាដើម : ដេកលើគ្រែ អង្គុយលើកៅអី (ព. រ.) ។
– លើក ( កិ. ) យកពីក្រោមឡើងទៅលើ, យកពីទំនាបទៅទីខ្ពស់; យកពីទីមួយទៅទីដទៃ; ជ្រោងឡើង, ទ្រឡើង, ស្ទួយឡើង; គ្រាហ៍ឡើង; ធ្វើឲ្យខ្ពស់, ដាក់បំពេញឬពូនឲ្យខ្ពស់ : លើកអីវ៉ាន់ពីដីដាក់លើផ្ទះ; លើកដៃ; លើកបាយ; លើកមនុស្សឈឺ, លើកដី, លើកថ្នល់, លើកភ្លឺស្រែ ។ លើកកំណាព្យ តែងកាព្យ ។ លើកកម្ពស់ អួតយកកម្ពស់ : និយាយលើកកម្ពស់; មនុស្សលើកកម្ពស់ ។ លើកខ្មោច គាស់ខ្មោច: បុណ្យលើកខ្មោច (ព. សា.); លើកខ្មោចស្រោចឆ្អឹង គាស់ខ្មោចហើយស្រោចទឹកលាងឆ្អឹង (ព. សា.) ។ លើកខ្លួន អួតខ្លួន, តម្កើងខ្លួន : និយាយលើកខ្លួន; មនុស្ស-- ។ លើកគ្នា នាំគ្នាច្រើននាក់ ។ លើកចោល បោះចោល; ចោលមិនយកជាការ, ចោលលែងត្រូវការ ។ លើកជើង សរសើរ ឬ បញ្ជោរនាំឲ្យឡើងទឹកចិត្តឬឲ្យបានចិត្ត, ឲ្យលង់ឬឲ្យស៊ុនគំនិត : និយាយលើកជើង ។ លើកដាក់ លើកឲ្យអង្គុយហើយដាក់ផ្ដេកទៅវិញ : ឈឺលើកដាក់ (ឈឺធ្ងន់ក្រោកមិនរួច) ។ លើកតម្កើង ធ្វើឲ្យថ្កើង : និយាយលើកតម្កើង ។ លើកទ័ព នាំកងទ័ពចេញទៅឬត្រឡប់មក ។ លើកទុក បញ្ឈប់ទុក, ស្លេះទុក; លើកលែង ។ លើកទោស ពោលទោស ។ លើកទោសចោល លែងប្រកាន់ទោស, បដិសេធទោស ។ លើកបំណន់ តាំងរៀបពិធីឬតាំងរបៀបបន់ស្រន់ ។ លើកមនុស្ស តម្កើងមនុស្ស : ស្រុកលើកមនុស្ស ។ លើកមុខ នាំឲ្យពេញមុខ, ឲ្យមានសេចក្ដីសរសើរ : កូនលើកមុខឪពុកម្ដាយ, សិស្សលើកមុខគ្រូ ។ លើកយក នាំយក : លើកយក

រឿងមកតំណាល ។ លើករាសី (ម. ព. រាសី) ។ លើករឿង តែងរឿងប្រតិដ្ឋចេញពីគំនិតខ្លួន ។ លើកល៉ៈ (< លើក ។ល។) រំលងចោលខ្លះមិនឲ្យសព្វគ្រប់ : និយាយលើកល៉ៈ ។ លើកលែង ឈប់លែង; បដិសេធចោល; វៀរលែង ។ លើកលែងតែ វៀរលែងតែ: លើកលែងតែមនុស្សពិការ ។ លើកសត្វ លើកគ្នាច្រើននាក់ចូលលុកព្រៃបង្អើលសត្វ ដើម្បីបាញ់ឬឲ្យជាប់ដោយនេសាទុបករណ៍ ។ លើកសព (--សប់) គាស់សព (ព. ខ្ព.; ព. សា. លើកខ្មោច) ។ លើកសពសំស្ការ (លើកសពសង្ការ) លើកសពសង្ខារ គឺគាស់សពហើយធ្វើឈាបនកិច្ច (ព. ខ្ព.; ព. សា. លើកខ្មោចស្រោចឆ្អឹង) ។ លើកស្លា លើកជំនូនធំជូនមាតាបិតាខាងស្រី ។ល។

( កិ. ជា ឧ. ) ចូរលើក !; ពាក្យបង្គាប់ឲ្យលើកអ្វីៗព្រមគ្នា ឬបង្គាប់សត្វពាហនៈ មាន គោក្របី ជាដើមឲ្យលើកជើង ។ លើក !

យោងតាមខ្លឹមសារខាងលើ យើងអាចបកស្រាយបានថា ពាក្យ«លើ»និង«លើក» មានទំនាក់ទំនងគ្នានៅន័យដែលមានន័យរួម។ ជាសន្និដ្ឋាន បច្ឆិមបទ[-ក] នៅក្នុងឧទាហរណ៍ខាងលើ វាមានតួនាទីសម្រាប់បង្កើតកិរិយាសព្ទពីនាមសព្ទឬយើងអាចនិយាយម្យ៉ាងទៀតថា បច្ឆិមបទ [-ក] គឺជាបច្ឆិមបទកិរិយានីយកម្ម ចំណែកឯន័យវេយ្យាករណ៍នៃបច្ឆិមបទនេះគឺ***សម្រាប់សម្គាល់លក្ខណៈខ្ពង់ខ្ពស់***។ ក៏ប៉ុន្តែ ការប្រើប្រាស់បច្ឆិមបទនេះនិងពាក្យឫស នៅក្នុងភាសាខ្មែរទំនើបមិនមានលក្ខណៈរួមនោះទេ ពីព្រោះវាមានលក្ខណៈល្អៀងគ្នាច្រើនតាមរយៈន័យ ហើយពេលខ្លះមិនមានន័យដូចគ្នាផងទេ និយាយរួមគឺន័យមានលក្ខណៈខុសគ្នាទាំងស្រុង ជាពិសេសពាក្យឫសមួយចំនួនមិនមានន័យអ្វីសោះ នៅក្នុងភាសាខ្មែរទំនើបដូចជា៖ ង៉េ-ង៉េក, តើ-តើក, បើ-បើក, ពើ-ពើក, វើ-វើក។

ពាក្យ«ង៉េ-ង៉េក» មិនមាននៅក្នុងភាសាខ្មែរទំនើបនោះទេ ប្រហែលជាពាក្យទាំងនេះមាននៅក្នុងភាសាខ្មែរបុរាណ។ ពាក្យ «តើ-តើក» មានន័យនៅក្នុងភាសាខ្មែរទំនើប។ តាមវចនានុក្រម តើ ជានិបាតសព្ទ «ពាក្យសម្រាប់និយាយប្រចួនបំពេញឲ្យលះសេចក្ដីសង្ស័យ ដូចពាក្យថា មិនមែនប្អូនខ្ញុំទេ មាខ្ញុំទេតើ; ដូច្នេះទេតើ; អ្នកមកតើមានការអ្វី ?; ធម៌ ៨ យ៉ាង តើគឺអ្វីខ្លះ ? (ម. ព. ទេតើ ផង) ។ «តើ» ជានាមសព្ទ គឺជាអន្ទាក់ដាក់ស្វា ឧទាហរណ៍ ស្វាជាប់តើ ។» ចំណែកឯ«តើក » វិញមានន័យថាជានាមសព្ទមានន័យថា« អាការៈរបស់ត្រីនៅក្រោមកន្លើត សណ្ឋានដូចកន្លើត ឧទាហរណ៍ កាត់តើកវាចេញ ។» ពាក្យ«បើជានិបាតសព្ទ ប្រសិន, ប្រសិនណាបើ, ប្រសិនណា, (ពាក្យស្មាន) ឧទាហរណ៍ បើមិនចេះទេ កុំធ្វើចេះ; បើមិនចង់ទេ កុំទៅ; ចោរនុ៎ះក្លាហានណាស់ បើឈ្មោះណាចាប់បាន រាជការនឹងឲ្យរង្វាន់ ។ » ចំណែកឯពាក្យ«បើកជាកិរិយាសព្ទមានន័យថា ទីទៃពីបិទ, ពីគ្រប, ខ្ទប់, រាំង គឺធ្វើឲ្យច្រហ, ឲ្យមានផ្លូវ មានទំនង; ព្រមឲ្យ; ចេញចាយ; បញ្ចេញ; បណ្ដោយតាម : បើកទ្វារ, បើកផ្លូវ, បើករបង, បើកប្រាក់...។ បើកកប៉ាល់ ឬ បើករថយន្ត ធ្វើ

ម៉ាស៊ីនកប៉ាល់ឬរថយន្តឲ្យដើរ កាន់ចង្កូតតម្រង់ឲ្យលឿនទៅតាមគន្លងតាមផ្លូវ ។ បើកក្ដោង លើកក្ដោងឲ្យជក់ខ្យល់ទាញនាំនាវាឲ្យលឿនទៅ ។ បើកដាក់ បើកប្រាក់ឬបើករបស់អ្វីៗដាក់ឲ្យប្រើមានកំណត់ ។ បើកដៃ បណ្ដោយឲ្យ... តាមត្រូវការ ។ បើកទឹក ទម្លាយផ្លូវឲ្យទឹកហូរ ។ បើកទូក ឬ បើកល្វែង ពង្រីកទូកឬល្វែងឲ្យរីកធំជាងពីមុន ។ បើកព្រះនេត្រ គូរឬឆ្លាក់សម្រេចឲ្យកើតបានជាភ្នែកទេវរូបឬជាព្រះនេត្រព្រះពុទ្ធរូប (មុខការសម្រាប់ជាងគំនូរឬជាងឆ្លាក់រូប) ។ បើកភ្នែក ព. ប្រ. យល់ជាក់ច្បាស់ ព្រមទាំងភ្ញាក់ខ្លួនប្រែគំនិត, មិនងងឹតដូចពីដើម ហាក់ដូចជាគេបើកភ្នែកមើលឃើញច្បាស់ ។ បើកឱកាស បើកវេលាទំនេរឲ្យ ។ បើកអំណាច បើកឲ្យធ្វើតាមអំណាចច្បាប់ ។ល។»

ពាក្យ«ពើ-ពើក» ពាក្យ«ពើ ជាកិរិយាសព្ទមានន័យថា ធ្វើកលមាយាហាក់ដូចពុំបានដឹង, ឮ, ឃើញ, យល់ : ធ្វើពើជាសួរ ។ ប្រើជា ន. ឬ គុ. ក៏បាន ឧទាហរណ៍ សួរដោយពើ; ពុតពើ, អាការពើ ។» ពាក្យ«ពើក ជានាមសព្ទ មមោកបឿនដែលក្រាស់ណាស់ មើលទៅឃើញហាក់ដូចជាឥតមានទឹកនៅពីខាងក្រោម ឧទាហរណ៍ ដើរលើពើក (ម. ព. ត្រឹប, បឿន ទៀតផង) ។»

- បែរ ( កិ. ) ងាកប្រែមុខទៅខាងឬមកក្រោយ; ងាកចេញឃ្លាតពីប្រក្រតីដើម; ត្រឡប់ : បែរ មុខ, បែរខ្នង; បែរចិត្ត ។ បែរបែក ងាកបែកឃ្លាតចេញពីគ្នា ។ បែរជា... និ. ត្រឡប់ជា... បែរជា ខានទៅវិញ ។
- បែក ( កិ. ) រយៈ, ឃ្លាតចេញពីគ្នា; សាយភាយ, ចេញព្រាតព្រោង ។ល។ បែកការ ធ្វើការកំបាំងឬសេចក្ដីកំបាំងឲ្យលេចឮសាយសុស នាំឲ្យខូចការ ។ បែកកុក (ចិ. កុ៎ក "ពួក, ក្រុម, ទីប្រជុំ; ស្រុក") បែកពួក ។ បែកខ្ញែក បែករាត់រាយប្រញាយចេញពីគ្នា ។ បែកខ្នែង ចេញខ្នែង ។ បែកខ្មោច ប្រព្រឹត្តក្នុងការស្មន់អន្ទករនឹងគ្នា លុះដល់មានញាតិណាមួយ (ច្រើនតែខាងស្រី) ឈឺចាប់ គេគន់គូរមើលតាមក្បួន ឬបន់ស្រន់បួរបាច់ទៅឃើញថាត្រូវខ្មោចមេបាធ្វើទើបគេចាប់ប្រកាន់ឲ្យសែនខ្មោចឲ្យគេ...។ បែកគំនិត ឬបែកប្រាជ្ញា កើតមានគំនិតឬប្រាជ្ញាថ្មីប្លែកៗផ្សេងៗជាងពីមុន ។ បែកចិត្ត ងាកចិត្តចេញលែងរាប់រក ។ បែកចំណេះ កើតមានចំណេះប្លែកៗឡើងជាងពីមុន ។ បែកញើស ចេញញើស ។ បែកបាក់ ឬ បាក់បែក បែកខ្លះបាក់ខ្លះខ្ទេចខ្ទី ។ ព . ប្រ. ដាច់ដោយប្ដីប្រពន្ធឬឈ្លោះទាស់គ្នានឹងបងប្អូនញាតិមិត្រ គឺបែកចិត្តលែងរាប់អានគ្នា ។ បែកពួក បែកចេញជាពួកៗ ដោយមានគំនិតយល់ខុសគ្នា ។ បែកមែក ចេញមែកលូតលាស់ចម្រើនឡើង ។ ព. ប្រ បែកជាកូនពូនជាចៅ គឺកើតមានកូនចៅសាយរាយច្រើនឡើង ។ បែករំហាច ជន់លេចសាយពេញវាលរហេរហាច (និយាយបានចំពោះតែទឹក) : ទឹកជន់សាយលិចវាលបែករំហាច ។ បែកសា វះសត្វតាយសាកឲ្យបែកបំពង់បស្សាវៈ ធុំក្លិនឆ្អេះខូចរសជាតិសាច់ ។ ព . ប្រ. និយាយបែកសា ឬ បែកសាយាមោ គឺនិយាយបែកពីនេះបែកពីនោះ មិនចេះចប់ ។ បែកសាមគ្គី បែកសេចក្ដីព្រមព្រៀងគ្នា ។ ព . ទ. បុ. បែកជាអូរហូរទៅជាស្ទឹង ឈ្លោះប្រកែករំលើកបើកកកាយពីតិចតួចផ្ដួចដាលរាលទៅជាធំ ហាក់ដូចជាទឹកហូរច្រោះកើតជាអូរ យូរៗទៅកើតបានជាស្ទឹង, ឬពុំនោះហាក់ដូចជាទឹកហូរធ្លាក់មកក្នុងអូរចុះតទៅក្នុងស្ទឹង ។ល។

បច្ឆិមបទ[-ក] ខាងលើមានន័យដោយឡែកខុសគ្នាពីន័យបង្ហាញជូនខាងលើ ពីព្រោះនៅពេលនេះ មានន័យថា«ឃ្លាតចេញពីគ្នាឬមិននៅជាមួយគ្នាទៅវិញ» ដូចគ្នានេះ ពាក្យមួយផ្សេងទៀតក៏មានន័យដូចគ្នាដែរគឺ ចា> ចាក។

**១.២. បច្ឆិមបទ -ង**

យើងពិនិត្យមើល នៅក្នុងពាក្យ«លើ-លើង, បែរ-បែង»។

-លើ ( និ. ) ខាងខ្ពស់, ដែលជាប៉ែកខាងខ្ពស់ ឧទាហរណ៍៖ លើដំបូល, លើ ពាន, លើគោក ។ ចំពោះត្រង់ ឧទាហរណ៍៖ ចាប់មន្ទិលលើមនុស្សម្នាក់ ។ ប្រើ អំណាច ឆ្ពោះទៅរក ឧទាហរណ៍៖ ត្រួតត្រាលើ, និយាយលើ ។ ល។ អា. និ. ពាក្យសម្រាប់ ទទួលរងដំណើរ

អំពីអកម្មកិរិយាមាន ពាក្យ ដេក, អង្គុយ ជាដើម ឧទាហរណ៍៖ ដេកលើ គ្រែ

អង្គុយលើ កៅអី (ព. វ.) ។

– លើង ( កិ. ) ធ្វើឲ្យលើង, គាស់រំលើង ឧទាហរណ៍ លើងគល់ឈើ, ជីកលើង ។

– បែរ ( កិ. ) ងាកប្រែមុខទៅខាងឬមកក្រោយ; ងាកចេញឃ្លាតពីប្រក្រតីដើម; ត្រឡប់ ឧទាហរណ៍ បែរមុខ, បែរខ្នង; បែរចិត្ត ។ បែរបែក ងាកបែកឃ្លាតចេញពីគ្នា ។ បែរជា... និ. ត្រឡប់ជា... បែរជាខានទៅវិញ ។

– បែង ( កិ. ) ចែក, រំលែក ឬចែករំលែក ឧទាហរណ៍ ក្នុង ១ ភាគបែងជា ៤ ។ បែងភាគ រំលែកជាចំណែក ។ នារាយណ៍បែងភាគ ព្រះនារាយណ៍ដែលបែងសរីរាវយវៈឲ្យកើតជារូបផ្សេងៗ មានបែងភាគមកកើតជាព្រះរាមជាដើម (ពោលតាមលទ្ធិព្រាហ្មណ៍) ។ បែង៣( កិ. ) បញ្ចេញស៊ុតដាក់លើអ្វីៗ ដែលមានក្លិនអសោច៍ (និយាយបានចំពោះតែរុយ) ឧទាហរណ៍ រុយបែងដំបៅគោ ។

បច្ឆិមបទ [-ង] គឺមានន័យដូចបច្ឆិមបទ [-ក] ដែរគឺ «ខាងលើ ខ្ពង់ខ្ពស់ និងន័យឃ្លាតពីគ្នាឬមិននៅជាមួយគ្នា»។

**១.៣. បច្ឆិមបទ -រ**

- ចា? យើងមិនអាចរកន័យឃើញនៅក្នុងវចនានុក្រមនោះទេ ក៏ប៉ុន្តែ ពាក្យនេះ លោក ហ្វូកហ្គូនីយ៉េរ ដាក់សមមូលទៅនឹងពាក្យ«to engrave» នៃភាសាអង់គ្លេស ដែលមានន័យថា«ចារឬឆ្លាក់»។

- ចារ១ ( កិ. ) ធ្វើរបងទាបដោយដោតចម្រឹងឲ្យជាចារឹក : ចារចំណារ ។ សរសេរដោយដែកចារ ឧទាហរណ៍៖ ចារសាស្ត្រា ។

- ចារ២ ( ន. ) ឈ្មោះឈើមានផ្កាសម្បុរក្រហម ក្លិនឆ្អាប ឧទាហរណ៍៖ ដើមចារ, ផ្កាចារ ។

តាមន័យជាភាសាអង់គ្លេសខាងលើគឺដូចគ្នា ក៏ប៉ុន្តែ ភាសាខ្មែរទំនើបមិនមានពាក្យ«ចា»ទេ យើងមានតែពាក្យ«ចារ»ប៉ុណ្ណោះ។ ហេតុដូច្នេះ ឧទាហរណ៍ខាងលើគឺគ្រាន់តែជាការលើកឧទាហរណ៍ ដើម្បីបង្ហាញអំណះអំណាងនៅក្នុងការពង្រឹងស្នាដៃរបស់ខ្លួនតែប៉ុណ្ណោះ។ មួយវិញទៀត នៅក្នុងភាសាខ្មែរ ពាក្យដែលមានព្យញ្ជនៈ«រ»ខាងចុងគឺបង្កើតឡើង ដើម្បីសម្គាល់កុំឲ្យមានការភាន់ច្រឡំទៅនឹងវេវចនសព្ទតែប៉ុណ្ណោះ ហើយពាក្យដែលមានព្យញ្ជនៈ«រ»ខាងចុងមានយ៉ាងច្រើន ដូចជា៖«កា-ការ, ខូ-ខូរ, គូ-គូរ, ងា-ងារ, ឆ្មា-ឆ្មារ, ផ្សា-ផ្សារ, មា-មារ, វា-វារ, ហៀ-ហៀរ, អា-អារ»។

## ១.៤. បច្ចិមបទ -ស

យើងពិនិត្យលើពាក្យ «លើនិងលើស» តាមន័យរបស់វចនានុក្រមខ្មែរដូចខាងក្រោម៖

- លើ ( និ. ) ខាងខ្ពស់, ដែលជាប៉ែកខាងខ្ពស់ : លើដំបូល, លើរាន, លើគោក ។ ចំពោះត្រង់ : ចាប់មន្ទិលលើមនុស្សម្នាក់ ។ ប្រើអំណាចឆ្ពោះទៅរក : ត្រួតត្រា លើ, និយាយលើ ។ល។ អា. និ. ពាក្យសម្រាប់ទទួលរងដំណើរអំពីអកម្មកិរិយា មានពាក្យ ដេក , អង្គុយ ជាដើម : ដេកលើគ្រែ អង្គុយលើកៅអី (ព. វ.) ។

- លើស ( កិ. ) ហួស, កន្លង : ចេះឥតមានអ្នកណាលើស ។ និ. ដែលហួស ប្រមាណ, ហួសពីចំនួន, កន្លង, ក្រៃលែង : ច្រើនលើស, ល្អលើសគេ, មានទ្រព្យ លើសគេ ។ លើសខ្វះ លើសឬខ្វះ, លើសខ្លះខ្វះខ្លះ ។ លើសប្រមាណ ហួស ប្រមាណ ។ លើសមាត្រ ហួសមាត្រ, លុបមាត្រ : ខ្លាំងលើសមាត្រ ។ លើស មាត្រា ហួសខ្នាត, លើសប្រមាណ; ហួសកម្រិតច្បាប់ ។ លើសលន់ លើសក្រៃ, លើសក្រៃពេក ។ លើសលស់ លើសខ្វះ, មិនសព្វគ្រប់; ឆ្គាំឆ្គង, ឃ្លាតឃ្លៀង ល្មៀងពីច្បាប់, ពីបែបបទ ។ លើសលុប (--លប់) លើសហួសកំណត់, ហួស ប្រមាណ ។ លើសលែង ក្រៃលែង; ពន់ពេក ។ លើសវិស័យ ហួសវិស័យ ។ លើស សម័យ កន្លងសម័យ ។ល។

តាមរយៈការបង្ហាញនិយមន័យខាងលើ ពាក្យ«លើនិងលើស» មានទំនាក់ទំនងគ្នាដូចគ្នាទៅនឹងបច្ចិមបទ«-ក និង -ង» ដែរ។ គូពាក្យបែបនេះ យើងសង្កេតឃើញមានជាច្រើននៅក្នុងភាសាខ្មែរទំនើប ដូចជា៖ «ទើ-ទើស, ពើ-ពើស, រើ-រើស»។ ទោះបីជាមានពាក្យពេចន៍បែបនេះនៅក្នុងភាសាខ្មែរទំនើបក៏ដោយ ក៏មិនមែនមានន័យថាដំណើរការនៃការប្រើប្រាស់បច្ចិមបទនៅ

ក្នុងភាសាខ្មែរទំនើបមាននោះទេ ហើយភាសាខ្មែរបុរាណបែបនេះក៏មានកម្រិតមួយមិនទូលំទូលាយផងទេ ជាពិសេសទៅទៀតនោះ ពាក្យពេចន៍បែបនេះក៏មិនជាសម្បូរបែបណាស់ណាទេនៅក្នុងភាសាខ្មែរទំនើប។

## ២. ការវិភាគបច្ច័មបទរបស់ លោក ហ្វ្រែងលីន ហាហ្វមែន

លោកហ្វ្រែងលីន ហាហ្វមែនបានពិពណ៌នាថា ភាសាខ្មែរមានបច្ច័មបទ ហើយ បច្ច័មបទនោះ លោកបរិយាយថាមានបីគឺ៖«-បី, -ម៉ាន, និង-សិប។» យើងសូមលើកយកគំនិតរបស់លោកមកបង្ហាញ ដូចខាងក្រោម[6]៖

*រូបតារចនាសព្ទរងមួយចំនួនដែលមាននៅក្នុងខាងចុងពាក្យមានន័យស្របគ្នា តាមរយៈវចនសព្ទយ៉ាងសំខាន់មួយចំនួន។ រូបតាខាងចុងពាក្យទាំងនោះបានវិភាគថាជាបច្ច័មបទ។*

### ២.១. ទីមួយ៖ បច្ច័មបទ /-បី/

បច្ច័មបទ/-បី/បង្កើតពាក្យកម្លាយជាសន្ធានស័ព្ទរណាប(subordinating Conjunction)

ឧទាហរណ៍

| | | |
|---|---|---|
| ដើម | > | ដើម្បី |
| កុំ | > | កុំបី |
| គាប់ | > | គប្បី |
| ទោះ | > | ទោះបី |

### ២.២. ទីពីរ៖ បច្ច័មបទ /-ម៉ាន/

បច្ច័មបទបង្កើតពាក្យកម្លាយដែលជាពាក្យបដិសេធន៍និងកិរិយាវិសេសន៍អនិយត

ឧទាហរណ៍

| | | |
|---|---|---|
| ប៉ុន | > | ប៉ុន្មាន |
| ស្មើ | > | ស្មើម៉ាន |
| អំបាល | > | អំបាលម៉ាន |

ពាក្យកម្លាយដែលកើតចេញពីបច្ច័មបទ/-ម៉ាន/អាចផ្សេងទៀតដូចជា៖ ប្រមាណ, ស្មាន។

---

6 Franklin E. Huffman, ***An Outline of Cambodian Grammar***, op.cit., p.106.

(*There are several sub-lexemic morphemes which occur in post-bound position with a consistent meaning in a significant number of lexeme. They are analyzed as suffixes.*)

### **២.៣. ទីបីៈ បច្ឆិមបទ** /-**សិប**/

បច្ឆិមបទ/-សិប/បង្កើតពាក្យកម្លាយជាច្រើនលើដប់។

ឧទាហរណ៍

សាម > សាមសិប

សែ > សែសិប

បច្ឆិមបទនេះ លោកហាហ្វមែន បានគូសបញ្ជាក់ថាជាប្រភេទបច្ឆិមបទដែលមានទម្រង់ខ្ចីមកពីភាសាថៃ ក៏ប៉ុន្តែ ឧទាហរណ៍ទាំងពីរនេះមានលក្ខណៈសាំញ៉ាំ ហើយលក្ខណៈទាំងនេះបានមកពីការសង្កេតពីទម្រង់«ហាសិបឬហុកសិប»។[7]

### **២.៤. ទីភាគបច្ឆិមបទ** /-**ប៊ី**/

ដូចបានពិពណ៌នារួចមកហើយ បច្ឆិមបទ/-បី/ មាននៅក្នុងពាក្យ«ដើម្បី, កុំបី, គប្បី, និងទោះបី»។ ប្រសិនបើយើងពិនិត្យជាដំបូង ចំពោះពាក្យ«ដើម្បី» តាមគំនិតខាងលើ ពាក្យ«ដើម្បី» មកពីពាក្យ«ដើម»និង«បី»។ ពាក្យ«ដើម»[8] គឺជានាមសព្ទដែលមានន័យថា« គល់, ភាគជាដំបូង, ជាមុន : ដើមដៃ, ដើមទ្រូង, ដើមផ្លូវ ។ សំណុំខ្លួន, តួខ្លួន : ដើមឈើ, ដើមពោត; ឈើ ១ ដើម, ឫស្សី ១ ដើម, ដែក ១ដើម ។ ដើមការ អ្នកផ្ដើមធ្វើការ, ម្ចាស់ការ (ប្រើចំពោះតែការកុសល ឬមង្គលការផ្សេងៗ) ។ ដើមគំនិត អ្នកផ្ដើមគិតជាមុនគេ ។ ដើមចម ដើមហេតុដែលជាធំក្នុងដំណើរ, ក្នុងរឿងអ្វីមួយ ។ ដើមចោទ អ្នកផ្ដើមចោទមុនគេ, រូបចោទក៏ ។ ដើមដង សំណុំ, លំនាំ, ទំហំ នៃដើមដំណាំផ្សេងៗ : ពោតឆ្នាំនេះ មានដើមដងល្អគ្រាន់បើជាងពីក្នុងឆ្នាំមុន ។ ដើមដំបូង គ្រាមុនបង្អស់ ។ ដើមទង ទងគន្លង, ទំនងជាមុនបង្អស់ ។ ដើមទុន ប្រាក់ដើម សម្រាប់ប្រកបការងារយកចំណេញ ។ ដើមទ្រព្យ ទ្រព្យដែលមិនចាយវាយទុកឲ្យនៅជាប្រធាន, ជាមេនៃទ្រព្យក្នុងផ្ទះ ។ ដើមបណ្ដឹង អ្នកប្ដឹងមុន ។ ដើមបុណ្យ អ្នកផ្ដើមធ្វើបុណ្យ (ម្ចាស់បុណ្យ) ។ ដើមហេតុ ហេតុដំបូង ។ ដើមឡើយ និ. កាលមុន, គ្រាដំបូង ។ ដើមអាទិ, ដើមធាន ឬ ដើមអាទិដើមធាន (អ. ថ. --អាត) អ្នកនាំផ្ដើមមុនគេ; ហេតុ, ដំណើរ, សេចក្ដីដែលផ្ដើមមុនបង្អស់ ។ល។» ចំណែកឯពាក្យ«បី» បើតាមវចនានុក្រមដដែលបញ្ជាក់ថាៈ«ចំនួនលេខដែលនៅត្រង់ចន្លោះពីរនិងបួន គឺមួយផ្សំនឹងពីរ ឬពីរផ្សំនឹងមួយ (៣) ។ ប្រភេទពាក្យទីពីរគឺកិរិយាសព្ទ មានន័យថាៈ កាន់ត្រកងឱបឬទ្រដោយដៃទាំងពីរ ឧទាហរណ៍ៈ បីកូន, បីតោក ។ ក្រៅពីនេះពាក្យ«បី»ក៏អាចផ្សំជាមួយពាក្យដទៃទៀតដូចជាៈ បីត្រកង (ព. ប្រ.) លើកតម្កើង, កាន់ជើង, កាន់ទ្រង់ ។ បីទ្រ (ព. ប្រ.) ជួយ

---

7 See: Franklin E. Huffman, ***An Outline of Cambodian Grammar***, op.cit. p.106.

8 សូមមើលៈ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ***វចនានុក្រមខ្មែរ*** ដ.ឯ.ម ទំព័រ៣១០-៣១១។

ឧបត្ថម្ភគាំទ្រ ។»

ប្រសិនបើ ក្នុងករណីពាក្យ«ដើម្បី» កើតមកពីពាក្យ«ដើម»និងបច្ឆិមបទ«-បី» ដូចគំនិតរបស់លោក ហ្វ្រែងលីន ហាហ្វមែនលើកឡើងនោះមែន អាស្រ័យហេតុនេះ ពាក្យដែលបានរៀបរាប់ខាងលើដែលផ្សំបង្កើតពីពាក្យ «ដើម» ក៏នឹងក្លាយទៅជាបច្ឆិមបទទាំងអស់ដូចជា«-បី»ដែរគឺ« -ការ, -គំនិត, -ចម, -ចោទ, -ដង, -ដំបូង, -ទង, -ទ្រព្យ, -បណ្ដឹង, -បុណ្យ, -ហេតុ, -ឡើយ, -អាទិ, និង -ធាន។» ទាំងអស់នេះដូចមាននៅក្នុងពាក្យដូចបានរៀបរាប់ខាងលើ( ដើមការ, ដើមគំនិត, ដើមចម, ដើមចោទ, ដើមដង, ដើមដំបូង, ដើមទង, ដើមទ្រព្យ, ដើមបណ្ដឹង, ដើមបុណ្យ, ដើមហេតុ, ដើមឡើយ, ដើមអាទិ, និងដើមធាន។) ក៏ប៉ុន្តែ ការពិត ពាក្យដែលផ្សំជាមួយនឹងពាក្យ «ដើម» បង្កើតបានជាពាក្យមួយទៀតដែលមានលក្ខណៈខុសពីពាក្យកម្លាយ ហើយ ន័យនៃពាក្យទាំងនោះមានការទាក់ទងគ្នា ដោយអន្លើ។ ម្យ៉ាងវិញទៀត ពាក្យទាំងនោះមានន័យពេញលេញដោយខ្លួនឯង ពោលគឺពាក្យខាងលើមិនមែនជាអព្ភាសបទទេ។ សូម្បីតែពាក្យ«បី»ខ្លួនឯង ក៏មានន័យពេញលេញរួចស្រេចទៅហើយ នៅក្នុងការប្រើប្រាស់ក្នុងភាសាខ្មែរទំនើប។ មួយវិញទៀតនោះ យោងតាមនិយមន័យ យើងអាចសន្និដ្ឋានបានថាពាក្យ«បី»ពិតណាស់មិនមែនជាបច្ឆិមបទ ពីព្រោះពាក្យ«បី»គឺជាវចនសព្ទឬជាពាក្យឫស។

ចំណែកឯពាក្យ«ដើម្បី» ទៀតសោត ក៏ជាពាក្យឫសផងដែរ ពីព្រោះថាពាក្យ«ដើម្បី»មិនទំនងជាកើតមកពីពាក្យ«ដើម»និង«បី»នោះទេ បើទោះណាជាភាសាខ្មែរមានពាក្យ«ដើម»និងពាក្យ«បី»ក៏ពិតមែន យ៉ាងណាក៏ដោយ ក៏ពាក្យ «ដើម្បី»មិនមានដំណើរការដូចលោក ហ្វ្រែងលីន ហាហ្វមែនលើក ឡើងនោះទេ យើងយល់ថាការបង្ហាញបែបនេះទំនងជាមានការភាន់ច្រឡំ។ ជាតឹកតាង យើងអាចបញ្ជាក់បានថា «ដើម្បី»គឺជាធ្នាក់ដែលមានន័យថា៖ ***បម្រុង, បម្រុងនឹង, សម្រាប់, សម្រាប់នឹង, ប្រយោជន៍នឹង : ពួកមនុស្សបានជាខំរៀន ខំរក ខំប្រព្រឹត្តសុចរិតស្លូតត្រង់ទាំងម្ល៉េះ តើដើម្បីអ្វី ? --ដើម្បីសេចក្ដីសុខ និងសេចក្ដីចម្រើន ។*** ជាសន្និដ្ឋាន ពាក្យ «ដើម្បី»គឺជាពាក្យឫស។

ពាក្យ«កុំបី» កើតមកពីពាក្យ«កុំ»និងពាក្យ«បី»។ យើងអាចស្វែងរកន័យរបស់ពាក្យ«កុំ» ដែលមានប្រភេទពាក្យជានិបាតសព្ទដែលមានន័យថា៖ ***ពាក្យបដិសេធន៍ឃាត់កិរិយាសព្ទទាំងពួងដោយមិនយល់ព្រម : កុំទៅ, កុំមក, កុំឲ្យ, កុំថាអ្វី, កុំពោលតាមតែកំហឹង,... ។ ប្រសិនបើ ប្រភេទពាក្យជាគុណនាមឬកិរិយាវិសេសន៍វិញមានន័យថាជុំ, ប្រមូលគ្នានៅជាជុំ, សម្បូរកុះករ : ទឹកត្រជាក់ត្រីកុំ, មានមនុស្សនៅកុះកុំ*** ។ ចំណែកឯពាក្យ«កុំបី» យើងមិនអាចរកឃើញជាមេពាក្យនៅក្នុងវចនានុក្រមខ្មែរឬវចនានុក្រមខ្មែរដទៃទៀតនោះទេ ក៏ប៉ុន្តែ យើងអាចរកឃើញពាក្យនេះនៅ

ក្នុងឧទាហរណ៍ដូចជា៖ ***គប្បីប្រព្រឹត្តឲ្យត្រឹមត្រូវទៀងទាត់តាមធម៌វិន័យកុំបីឲ្យឃ្លាត***។

ពាក្យ«គប្បី» តាមលោក ហាក់ហ្មែនថាមកពីពាក្យ«គាប់»និងបច្ឆិមបទ«បី»។ យើងអាចសង្កេតមើលតាមន័យរបស់ពាក្យទាំងពីរនេះ។ ពាក្យ«គាប់»មានប្រភេទពាក្យជាគុណនាមដែលមានន័យថា៖ ***ត្រូវ, ឥតខុស, ឥតទាស់ : អ្នកហ្នឹងគេគាប់នឹងចៅហ្វាយគេណាស់, គាប់ចិត្ត ; គាប់ប្រសើរ; គាប់គួរ; មានក្ដីគាប់ ។ ពាក្យផ្ទុយនឹង ខុស,ទាស់; មិនត្រូវចិត្ត*** ។ ចំណែកឯ ពាក្យ«គប្បី» វិញ បើតាមវចនានុក្រម «គប្បី»មានប្រភេទអាយតនិបាតពាក្យជាន័យថា៖ ***ត្រូវតែ ឧទាហរណ៍ អ្នកបួសគប្បីខំប្រឹងសិក្សារៀនសូត្រ, គប្បីប្រព្រឹត្តឲ្យត្រឹមត្រូវទៀងទាត់តាមធម៌វិន័យ កុំបីឲ្យឃ្លាត ។ ជួនកាលប្រើជា កិ. វិ. ដូចពាក្យថា ប្រព្រឹត្តមិនគប្បី ជាដើម ។ គាប្បី***

ពាក្យ“ទោះបី” តាមគំនិតរបស់លោក ហាក់ហ្មែនថាកើតមកពីពាក្យ“ទោះ”និង“បី”។ យើងពិនិត្យមើលន័យរបស់ពាក្យទាំងពីរតាមវចនានុក្រម ពាក្យ“ទោះ”មានប្រភេទពាក្យជាឈ្នាប់ ហើយវាមានន័យថា៖ ***ទុកជា, បើជា, បើទុកជា : ទោះល្អក្ដី អាក្រក់ក្ដី; ទោះខ្ញុំបានមកក្ដី មិនបានមកក្ដី ត្រូវតែអ្នកចាត់ការនុ៎ះចុះ*** ។ ចំណែកឯពាក្យ«ទោះបី»ក៏មានប្រភេទពាក្យជាឈ្នាប់ផងដែរ ដែលមានន័យថា៖ ***ទុកណាជា, បើទុកណាជា, ក្រែងលោ ឧទាហរណ៍៖ ពាក្យដែលខ្ញុំបានថ្លែងមកទាំងប៉ុន្មាននុ៎ះ ទោះបីមានលើសលស់ផ្ដាំផ្ដង សូមអ្នកទាំងឡាយអត់ទោសខ្ញុំ !*** មួយវិញទៀតនោះ ពាក្យ«ទោះ»ក៏មានលទ្ធភាពសម្រាប់បង្កើតពាក្យដទៃទៀតដូចជា៖ ទោះជា, ទោះណាជា, ទោះបីបើ, ទោះម្ដេចក្ដី, ទោះយោបី, ជាដើម ហើយ ពាក្យទាំងនេះគឺជានិបាតសព្ទឬឈ្នាប់សម្រាប់ប្រើភ្ជាប់ទៅនឹងល្បះរងឬល្បះតូច។

ជាសន្និដ្ឋាន ពាក្យខ្លះដែលកើតឡើងពីពាក្យឫសចូលផ្សំជាមួយពាក្យ«បី» ហើយក៏ដោយក៏ពាក្យទាំងនេះបានរលាយចូលគ្នាបង្កើតបានជាប្រភេទពាក្យមួយផ្សេងទៀតដែលមានន័យច្បាស់លាស់ ហើយ មិនមានការរលាយចូលគ្នា ដើម្បីបង្កើតបានប្រភេទពាក្យមួយផ្សេងទៀតមានន័យច្បាស់លាស់ ដោយមិនមានការជាប់ទាក់ទងទៅនឹងពាក្យ«បី»នោះផងទេ។ ការណ៍នេះសបញ្ជាក់ឲ្យឃើញថា កន្សោមពាក្យដែលកើតឡើងពីពាក្យ«បី»គឺបានក្លាយទៅជា***ពាក្យមួយថ្មី*** ហើយខ្លះទៀត ក៏បានរលាយចូលគ្នា ក្នុងការបង្កើតជា***ពាក្យសមាស***ដែលមានប្រភេទពាក្យជានិបាតសព្ទឬឈ្នាប់ រួចទៅហើយ។ ជាលទ្ធផល យើងគួរអះអាងថាពាក្យ«ដើម្បី, កុំបី, គប្បី, និងទោះបី» គឺជាពាក្យឫស ហើយមិនគួរគប្បីណា ចាត់ប្រភេទពាក្យបែបនេះជាប្រភេទពាក្យកម្លាយនោះទេ។

### ២.៥. វិភាគបច្ឆិមបទ /-ម៉ាន/

ដូចលោក ប្រៀងលីន ហាហ្វមែនបញ្ជាក់ខាងដើមរួចមកហើយថា ពាក្យ«ប៉ុន្មាន, ស្មើម៉ាន, អំបាលម៉ាន, និងស្មាន» គឺជាពាក្យកម្លាយដែលកើតពាក្យឫស «ប៉ុន, ស្មើ, និងអំបាល» ផ្សំជាមួយបច្ឆិមបទ /-ម៉ាន/ ។ ដោយឡែកពាក្យ«ប្រមាណ,ស្មាន» លោកមិនបានប្រាប់ឲ្យដឹងនូវឫសគល់នោះផងទេ ដោយលោកគ្រាន់តែបញ្ជាក់ថាជាពាក្យកម្លាយដែលកើតចេញមកបីបច្ឆិមបទ/-ម៉ាន/ ប៉ុណ្ណោះ។

បច្ឆិមបទ /-ម៉ាន/ លោកបានពន្យល់ថា **ប៉ុន្មាន**។ តាមការសង្កេតរបស់យើង យើងរកមិនឃើញពាក្យ«ម៉ាន» ទាំងភាសាខ្មែរបុរាណនិងទំនើបនោះទេ ក៏ប៉ុន្តែ យើងអាចរកឃើញពាក្យ «មាន» ទៅវិញ។ លោក ប្រៀងលីន ហាហ្វមែនបានពិពណ៌នាថាពាក្យ«ប៉ុន្មាន» កើតមកពីពាក្យ «ប៉ុន» និង «ម៉ាន» ប៉ុន្តែ តាមពិតទៅ ពាក្យ«ប៉ុន្មាន»កើតមកពីពាក្យ«ប៉ុន»និង«មាន» ទៅវិញ។[9] តាមវចនានុក្រម ពាក្យ«ប៉ុន្មាន» មានប្រភេទពាក្យជានិបាតសព្ទដែលមានន័យថា៖ *ពាក្យសម្រាប់សួរឲ្យដឹងចំនួនអ្វីៗ ឧទាហរណ៍៖ មនុស្សប៉ុន្មាននាក់ ? ប្រាក់ប៉ុន្មានរៀល ?* ពាក្យ«ប៉ុន»និង«មាន» គឺ ជាពាក្យឫសមានន័យពេញលេញដូចគ្នា។ ពាក្យ«ប៉ុន»គឺមានប្រភេទពាក្យជានិបាតសព្ទហើយមានន័យថា៖ *ស្មើ, ដូច, មិនលើសខ្វះពីគ្នា : ប៉ុនណា ?, ប៉ុនគ្នា, ប៉ុនកដៃ ។ ភ្ញាក់ប៉ុនគេចោល គឺ ភ្ញាក់ព្រើត ដូចគេចោលដុំអ្វីមួយប៉ះត្រូវខ្លួន ។ ប្រើជា គុ. ក៏មាន : មានទំហំប៉ុនគ្នា ។ គ្រាមភាសាប្រើក្លាយជា ប៉ិន (ម. ព. នោះ) ។* ចំណែកពាក្យ«មាន»មានប្រភេទពាក្យជាកិរិយាសព្ទ ហើយវាមានន័យថា៖ *បាន, កប, ប្រកបដោយ, កើត, បរិបូរដោយ, គង់នៅ, ឋិតនៅ... ។ ព. ផ្ទ. គ្មាន, ឥត ។ មានកម្ម មានអំពើដែលធ្វើទុកមកពីនាយ; ច្រើនសំដៅសេចក្ដីចំពោះអំពើអាក្រក់ : មនុស្សមានកម្ម ។ មានកូន បានកូន (ព. ផ្ទ. គ្មានកូន, ឥតកូន) ។ មានកំណើត ដែលធ្វើអ្វីៗចេះតែកបកើតប្រយោជន៍, មានសំណាង : មនុស្សមានកំណើត (ព. ផ្ទ. ឥតកំណើត) ។ មានខ្មាស បរិបូរដោយសេចក្ដីខ្មាស : មនុស្សមានខ្មាស (ព. ផ្ទ. គ្មានខ្មាស, ឥតខ្មាស) ។ មានខ្លួន មានរូបនៅជាអាង (ព. ផ្ទ. បាត់ខ្លួន) ។ មានគុណ ដែលប្រកបដោយគុណ ។ មានគូស្រករ, មានគូគ្រងស្រករគ្នា, ឬ មានគ្រួសារ, មានផ្ទះ, មានផ្ទះសំបែង មានប្ដីប្រពន្ធ ។ មានគំនិត ដែលមានការគិតច្រើន, មានមារយាទ (ព. ផ្ទ. ឥតគំនិត) ។ មានចិត្ត ឬ មានចិត្តមានថ្លើម ដែលបរិបូរដោយសេចក្ដីប្រឹងប្រែង មិនច្រអូស, មិនទម្រន់, មិនមើលបំណាំ (ព. ផ្ទ. ឥតចិត្ត ឬ ឥតចិត្តឥតថ្លើម គឺខ្ជិល, ច្រអូស, ទម្រន់, មើលបំណាំ) ។ មានចំណេះ បរិបូរដោយការចេះដឹង, មានវិជ្ជា : មនុស្សមានចំណេះ (ព. ផ្ទ. ឥតចំណេះ, ល្ងង់ ។ មានច្បាប់ ដែលកាន់ត្រឹមត្រូវតាមច្បាប់, ដែលប្រកាន់តែតាមច្បាប់ឬដែលមានសុភាពរាបសា ចេះគួរចេះសមមិនឆ្គង : មនុស្សមានច្បាប់ (ព. ផ្ទ. ឥតច្បាប់, ប្រហើន) ។ មានជីវិត គង់*

---

9 សូមមើល៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ *វចនានុក្រមខ្មែរ* ជ.ឯ.ម. ទំព័រ៦៣១។

*ជីវិតនៅ, រស់នៅ (ព. ផ្ទ. អស់ជីវិត, ស្លាប់) ។ មានជោគ មានស្រីសួស្ដី (ម. ព. ជោគ ទៀតផង) ។ មានឈ្មោះ ឬ មានកេរ្តិ៍ឈ្មោះ ដែលលេចឮល្បីកេរ្តិ៍ឈ្មោះល្អ ។ មានដំណើរ មានរឿង, កើតក្ដី ។ មានតម្រិះ ដែលចេះត្រិះរិះត្រូវ; និយាយឲ្យពេញថា មានតម្រិះត្រូវ, មានតម្រិះល្អ (ព. ផ្ទ. គ្មានតម្រិះ, ឥតតម្រិះ គឺមានតែខាងការត្រិះរិះខុស, ត្រិះរិះអាក្រក់) ។ មានត្រកូល ឬ មានជៅ, មានពូជ, មានអម្បូរ ដែលកើតក្នុងត្រកូលខ្ពស់ឬត្រកូលមានកេរ្តិ៍ឈ្មោះ (ព. ផ្ទ. ឥតត្រកូល, ឥតពូជ, ឥតអម្បូរ គឺដែលកើតក្នុងត្រកូលថោកថយ...) ។ មានទុក្ខ កើតទុក្ខ ។ មានទ្រព្យ ឬ មានសម្បត្តិ ដែលបរិបូរដោយទ្រព្យសម្បត្តិ (ព. ផ្ទ. ខ្សត់ទ្រព្យ, ក្រីក្រ, ទ័ល, ទ័លក្រ ។ មានធម៌ ដែលប្រព្រឹត្តឬប្រកាន់សុចរិតឬដែលមានចិត្តប្រកបដោយមេត្តា ករុណា; និយាយថា មានធម៌សប្បុរស ក៏បាន (ព. ផ្ទ. ឥតធម៌ ឬ គ្មានធម៌សប្បុរស) ។ មាននៅ កំពុងតែមាន, ដែលឋិតនៅ ។ មានបុណ្យ មានភ័ព្វ, មានសំណាងខ្ពស់, មានយសស័ក្តិ... (ព. ផ្ទ. ឥតបុណ្យ ។ ម. ព. បុណ្យ ទៀតផង) ។ មានពុត ដែលមានចិត្តរបិញរបុញ (ព. ផ្ទ. ស្លូតត្រង់) ។ មានព្រលឹង (ព. គ.) មានសាច់, ធាត់ (ព. ផ្ទ. មិនសូវមានព្រលឹង គឺស្គម) ។ មានព្រេង ឬមានសំណាង មានអំពើកសាងមកពីព្រេងនាយ (ព. ផ្ទ. ឥតព្រេង ឬ ឥតសំណាង) ។ មានព្រះអង្គ (រ. ស. ឬ ស. ស.) ធាត់ (ព. ផ្ទ. ពុំសូវមានព្រះអង្គ គឺស្គម) ។ មានភ័ព្វ មានសំណាងគួរដល់សេចក្ដីសុខ-ចម្រើន, គួរឲ្យអ្នកធំសង្គ្រោះបាន : មនុស្សមានភ័ព្វ (ព. ផ្ទ. ឥតភ័ព្វ, អភ័ព្វ) ។ មានមារយាទ ដែលមានមារយាទល្អ, ដែលមានឫកពានឹងធឹង, ស្លូតបូត : ក្មេងមានមារយាទ គឺក្មេងដែលនឹងធឹង, មានសណ្ដាប់ធ្នាប់, មានរបប (ព. ផ្ទ. ឥតមារយាទ, ឥតរបប, រពឹស) ។ មានមុខ ឬ មានមុខមាត់, មានមុខមានឈ្មោះ ដែលអាចចេញមុខក្នុងទីប្រជុំបាន, ដែលមានអ្នកធំអ្នកតូចរាប់អានច្រើន ។ល។ អ្នកមាន អ្នកបរិបូរដោយទ្រព្យសម្បត្តិ (ព. ផ្ទ. អ្នកក្រ) ។ល។*

នេះសបញ្ជាក់ឲ្យឃើញថា ពាក្យ«ប៉ុន្មាន» កើតមកពីពាក្យ«ប៉ុន»និង«មាន» ហើយពាក្យទាំងពីរនេះគឺជាពាក្យឫស។ ដូច្នេះ យើងអាចសន្និដ្ឋានបានថាពាក្យ«ប៉ុន្មាន»គឺជាមិនមែនជាពាក្យកម្ចាយនោះទេ វាគឺជាពាក្យឫសនៅក្នុងភាសាខ្មែរទំនើបទោះបីជាវាមានប្រភពនិងបន្សំបង្កើតបានជាពាក្យ«ប៉ុន្មាន»នេះក៏ដោយ ពីព្រោះថានៅក្នុងភាសាខ្មែរទំនើប ពាក្យ«ប៉ុន្មាន»គឺជាពាក្យមួយដែលគេប្រើទូទៅសម្រាប់សម្គាល់បញ្ញត្តិមួយរួចទៅហើយ។

*ពាក្យ«ស្មើម៉ាន»មកពីពាក្យ«ស្មើ»និង«ម៉ាន» លោកប្រែ្យងលីន ហាហ្វមែនបានពន្យល់ថាពាក្យ«ស្មើម៉ាន»និងពាក្យ«ប៉ុន្មាន»មានន័យដូចគ្នា។ ការពន្យល់បែបនេះមិនសមទំនង ចំពោះអត្ថន័យនៃពាក្យ«ស្មើម៉ាន»នោះទេ ពាក្យ«ស្មើម៉ាន»គួរតែជាពាក្យដែលមានប្រភពមកពីពាក្យ«ស្មើ» និង«មាន»។* ហើយពាក្យ«ស្មើ»មានប្រភេទពាក្យជាគុណនាមឬកិរិយាវិសេសន៍ ហើយមានន័យថា៖ *ដែលប៉ុនគ្នា, ត្រូវគ្នា, មិនលើសមិនខ្វះពីគ្នា; រាបដូចគ្នា (យ៉ាងផ្ទៃស្គរ); ដែលជាកណ្ដាលមិន*

*លម្អៀងទៅរកខាងណា : ទម្ងន់ស្មើគ្នា, កម្លាំងស្មើគ្នា; តាំងចិត្តស្មើ, រាប់អានស្មើ ។ ស្មើភាគ ភាគប៉ុនគ្នា ។ ស្មើភាព ភាពស្មើគ្នា ។ ស្មើមុខ មានមុខការនិងអំណាចដូចគ្នា ។ ស្មើដោយ និ. ប្រាកដដោយ, ស្មើនឹង, ដូចជា ។ ស្មើនឹង និ. ដូចគ្នានឹង ។ ស្មើហើយ ! អស់ហើយ ! (ព. ត.) ។ គ្នាស្មើ គុ. ដែលមានភាពស្មើគ្នា : មនុស្សគ្នាស្មើ ។ល។* ដូច្នេះ ពាក្យ«ស្មើម៉ាន»ក៏អាចជាពាក្យឫសផងដែរ ហើយពាក្យនេះទំនងជាមានន័យថា៖ ពេលណា ម៉ោងណា?

ពាក្យ«អំបាលម៉ាន»មានន័យដូចគ្នាទៅនឹងពាក្យ«ប៉ុន្មាន»ដែរគឺ៖

**អំបាលម៉ានឬអម្បាលម៉ាន៖** ប៉ុន្មាន, ម្ល៉ា, យ៉ាងណា: ល្អអម្បាលម៉ានទៅ ?; ធំ អម្បាលម៉ានក៏ដោយ ! ។ ព. ទ. បុ. ពិសាក្រៃ ណានឹងឃ្លាន អាក្រក់ អម្បាលម៉ាន ក្រៃណានឹងគាប់ចិត្ត ឆ្ងាញ់ព្រោះឃ្លាន ទោះរូបអាក្រក់យ៉ាង ណាក៏ដោយស្រេចហើយនឹងគាប់ចិត្ត ។ អម្បាលយ៉ាង ឬ អម្បាលដូចយ៉ាង ប្រហែលដូចយ៉ាង : អម្បាលដូចយ៉ាងខ្ញុំ វាហ៊ានស្ដីឲ្យខ្លាំងៗឥតញញើត ។ អម្បាលអី ? ប្រហែលនឹងអ្វី ? ។ ប៉ុនអម្បាល ទុកជា, សូម្បី : ប៉ុនអម្បាលឪពុក វាម៉េច វាមិនស្ដាប់, ចំណង់បើខ្ញុំធ្វើម្ដេចវានឹងស្ដាប់ ! អំបាល

**អំបាលឬអម្បាល** (និ.) ដូចជា, ប្រហែលដូច, ប្រហែលដូចជា : អម្បាលលោក សង្ឃម៉េច វាហ៊ានដេរ, ចំណង់បើយើងជាគ្រហស្ថ វាខ្លាចអ្វីវា ! ។ អម្បាលដូច ដូចយ៉ាង : អម្បាលដូចខ្ញុំ។ អម្បាលណា ? ត្រឹមណា ?, ប៉ុនណា ?, យ៉ាងណា ? : ល្អអម្បាលណាទៅ ?, ឆ្ងាយអម្បាលណាទៅ ? ។ អម្បាលថ្ងៃ ? ប៉ុន្មានថ្ងៃ ? (ប្រ. ប្រ. អម្បាលង៉ៃ ព. សា.) ។

ជាសន្និដ្ឋាន ពាក្យ«អំបាលម៉ាន»កើតមកពីពាក្យ«អម្បាលឬអំបាល»ហើយនឹងពាក្យ«មាន» ហើយពាក្យនោះមានប្រើនៅក្នុងភាសាខ្មែរទំនើបទៀត។

ចំពោះពាក្យ«ប្រមាណ»និង«ស្មាន»វិញគឺមានន័យប្រហាក់ប្រហែលគ្នា។ យើងអាចវិភាគថាតើពាក្យ «ប្រមាណ» កើតមកពីពាក្យឫសនិងបច្ឆិមបទ/-ម៉ាន/មែនឬមិនមែន? តាមសូរវិទ្យាពាក្យនេះគួរតែកើតមកពាក្យឫស«មាន»និងបុព្វបទ/ប្រ-/ ចំណែកវចនានុក្រមខ្មែរបង្ហាញថា ពាក្យ«ប្រមាណ»គឺជាពាក្យដែលមានប្រភពមកពីសំស្ក្រឹតបាលីថា«បមាណ»៖

ប្រមាណ -ម៉ាន សំ.; បា. ( ន. ) (បមាណ) ការរាប់, ការស្ទង់, គ្នេរ, ស្មាន, ចំនួន; ពាក្យ, សេចក្ដីដែលគួររាប់គួរយកជាការពិតបាន; ការកំណត់ឬស្ទង់ ដំណើរ : ធ្វើការនិមន្តស្គាល់ ប្រមាណ; មនុស្សមិនស្គាល់ប្រាណខ្លួន; នឹងយក ពាក្យនេះជាប្រមាណពុំបាន, សេចក្ដីនេះគួរ យកជាប្រមាណបាន ។ល។ កិ. រាប់, ស្ទង់ការ, ស្ទង់ដំណើរ; គ្នេរ ដោយស្មាន :

ប្រមាណការ មិនត្រូវ, មាន ច្រើនណាស់នឹងរាប់ពុំបានប្រមាណពុំអស់ឡើយ ។ល។

ដូច្នេះ ពាក្យ«ប្រមាណ»ដូចបានរៀបរាប់ខាងលើគឺជាពាក្យឫស ហើយវាមានន័យពេញលេញជាពាក្យពិតប្រាកដនិងមានប្រភពចេញមកពីបាលីសំស្ក្រឹតថែមទៀតផង។

ពាក្យ«ស្មាន» តាមសូរវិទ្យាគឺជាពាក្យដែលកើតមកពីពាក្យ«មាន»និងបុព្វបទ/ស-/ ទៅវិញ ។ ន័យរបស់ពាក្យ«ស្មាន»តាមវចនានុក្រមៈ

ស្មាន១ ( កិ. ) នឹកប្រមាណ, កាត់ប្រមាណ, ស្ទង់ដោយកាត់ប្រមាណ : ខ្ញុំស្មានមិនខុស ។ ស្មានជា និ. ក្រែងលោ, ចូនក្រែង : ស្មានជាគេនឹងមក ។ ស្មានថា កិ. នឹកប្រមាណថា : កូនស្រីសោះ ស្មានថាជាប្រុស ។ល។

ស្មាន២ ( ប. ) ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ស្ម័គ្រ, ស្មោះ ថា : ស្ម័គ្រ ស្មាន (ម. ព. ស្ម័គ្រ) ។ ស្មោះស្មាន (ម. ព. ស្មោះ) ។

ដូច្នេះ ពិតណាស់ពាក្យ«ស្មាន»គឺជាពាក្យឫស ហើយចំណែកការពន្យល់របស់លោក ប្រៀងលីន ហាហ្វមែនថាជាពាក្យកម្លាយនោះ គឺមិនមានមូលដ្ឋាននិងទិន្នន័យច្បាស់លាស់ទេ។

**២.៦. វិភាគបច្ឆិមបទ /-សិប/**

លោក ប្រៀងលីន ហាហ្វមែនបានអះអាងថាពាក្យ«សិប»មានប្រភពមកពីភាសាថៃ។ ការសន្និដ្ឋានបែបនេះហាក់ដូចជាមិនសមហេតុសមផលនោះទេ ពីព្រោះថាពាក្យ«សិប»ទំនងជាមានប្រភពមកពីភាសាចិនច្រើនជាង។ ដោយសារថា ភាសាចិនទាជីវមានពាក្យ«ស៊ីប»ដែលមានន័យថា«ដប់»នៅក្នុងភាសាខ្មែរ។ ការណ៍នេះធ្វើឲ្យយើងយល់ថា ពាក្យ«សិប»គឺជាពាក្យសម្រាប់ការរាប់ចំនួន ដូច្នេះយើងអាចគូសបញ្ជាក់ថា ពាក្យ«សិប»មិនអាចមានហេតុផលណាអះអាងថាជាបច្ឆិមបទនោះទេ។ ជាលក្ខណៈសមហេតុសមផល ពាក្យ«សិប»គួរជាពាក្យសម្រាប់បង្កើតពាក្យសមាសទើបត្រឹមត្រូវជាង ហើយពាក្យសមាសប្រភេទនេះសម្រាប់រាប់ចំនួនដូចជា ***សាមសិប សែសិប ហាសិប ហុកសិប*** ជាដើម។

ជាសន្និដ្ឋាន តាមរយៈការវិភាគនិងលើកឧទាហរណ៍ខាងលើ ពាក្យ«បី, ម៉ាន, និងសិប»មិនមានភស្តុតាងណាមួយដែលអាចធ្វើឲ្យយើងអះអាងថាជា បច្ឆិមបទបាននោះទេ ពីព្រោះ ពាក្យទាំងបីនេះមានប្រភពនិងការប្រើប្រាស់ច្បាស់លាស់នៅក្នុងភាសាខ្មែរ។ ជាលទ្ធផល ពាក្យទាំងបីខាងលើគឺជាពាក្យឫស។